គណៈកម្មាធិការព្រំដែនកម្ពុជា
សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ
Comité des Frontières du Cambodge ( C F C )
Cambodia's Border Committee ( C B C )
ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

CFC-CBC 01102012K

# ស្ថានភាពយុទ្ធសាស្ត្រនៃកោះត្រល់ និងខ្សែបន្ទាត់«ប្រេវីយេ»

(ដោយ **ឌី ការ៉េត**)

## ស្ថានភាពយុទ្ធសាស្ត្រនៃ កោះត្រល់ និងខ្សែបន្ទាត់«ប្រេវីយេ»

នាកណ្តាលសតវត្សទី១៩ កម្ពុជាបីតក្នុងស្ថានភាពទន់ខ្សោយជាខ្លាំង ថ្វីត្បិតតែបានរំដោះខ្លួន ចេញពីនឹមអាណានិគមយួន (វៀតណាម) ក្តី។ តាំងពីដើមសតវត្សហ្នឹងមក ពួកស្តេចរាជាធិរាជយួន តែងចាត់ទុកកោះខ្មែរ «ត្រល់» (យួនហៅថា «ភូកុក») ថាជាទឹកដីនៃចក្រភពអាណ្ណាម (យៀកណាម សព្វថ្ងៃ) ប៉ុន្តែខ្មែរក៏តែងតែបានជំទាស់ ជាដាច់ខាត ជានិច្ចកាលដែរ។ លុះបារាំងអាណានិគម ចូលមកត្រួតត្រាឥណ្ឌូចិន ពីពាក់កណ្តាលសតវត្សទី១៩ មក បារាំងមិនហ៊ានដោះស្រាយ អំពីបញ្ហាកម្មសិទ្ធិ នៃកោះនេះទេ។ ទាល់តែជិត ១០០ ឆ្នាំបន្ទាប់មក ទើបលោក **ហ៊្សុល ប្រេវិយេ** (Jules Brévié) **ជាអគ្គទេសាភិបាលនៃឥណ្ឌូចិន បានសម្រេចម្នាក់ឯង នាថ្ងៃទី ៣១ មករា ១៩៣៩ ដាក់កោះត្រល់ នៅក្រោមរដ្ឋបាល នៃដែនកូសាំងស៊ីន ដែលជាអាណានិគមរបស់បារាំង ដោយលោកបានបញ្ជាក់ដែរថា នេះជាការសម្រេច លើផ្ទៃរដ្ឋបាល ប៉ុណ្ណោះទេ មិនមែនជាការសម្រេច លើបញ្ហាអធិបតេយភាព នៃកោះត្រល់ទេ។**

## កោះត្រល់ នាសតវត្សទី១៩

ឈ្មោះ«កោះត្រល់» គឺជាឈ្មោះដែលខ្មែរ បានស្គាល់ជាយូរយាមកហើយ។ គេបានឃើញពាក្យ «កោះ» សរសេរលើផ្ទាំងថ្ម តាំងពីសម័យអង្គរ។ នៅសតវត្សទី១៩ ពួកសៀម (ថៃ) ក៏ស្គាល់តែឈ្មោះ«កោះត្រល់» ដែលជាកោះរបស់ខ្មែរដែរ។ ពាក្យយួន«ភូកុក» ប្រហែលជាកើតមាន កាលពេលស្តេចយួនឈ្មោះ **«ង្វៀង ភុក អាន់» ឬ «ង្វៀង អាន់»** (អនាគតរាជាធិរាជ យ៉ាឡុង) ដែលបានមកជ្រកនៅលើកោះត្រល់ហ្នឹង ពីឆ្នាំ១៧៨២ ទៅ ១៧៨៦ ដោយត្រូវបានពួកតៃសឹង វាយកំចាត់ពីអាណ្ណាម ហើយភៀសខ្លួនទៅស្រុកសៀម មុននិងមកសុំជ្រកកោន នៅស្រុកខ្មែរ។ ស្តេចយួន ង្វៀង ភុក អាន់ នេះ បានទាំងសុំជំនួយកងទ័ពខ្មែរធំមួយ ពីស្តេចខ្មែរ **ព្រះអង្គអេង** ដើម្បីវិលទៅច្បាំងដណ្តើមរាជ្យ ពីពួកតៃសឹងវិញផង។ ប៉ុន្តែ ទម្លាប់របស់ពួកយួន គឺគេផ្លាស់ឈ្មោះដើម នៃស្រុកទេសរបស់អ្នកជិតខាងទាំងអស់ និងដាក់ឈ្មោះយួនវិញ ទោះជាគេបានទៅនៅទីនោះជាជនមកជ្រកកោនក្តី និងមួយរយៈកាលក្តី។

C/O M. SEAN - 8, Ave du Golf 77600 Bussy St Georges France - http://www.cfcambodge.org
Téléphone : +33(0)607 955 366 - Fax : +33(0)160 951 281 - Email : secretariat@cfcambodge.org

នាខែមិថុនា ១៨៥៦ អ្នកការទូតបារាំង ឈ្មោះ **សាល ដឺ ម៉ុងទីញី** (Charles de Montigny) បានមកដល់ស្រុកសៀម ហើយបានចុះសន្ធិសញ្ញាមួយ នាខែសីហា ជាមួយសៀម ស្តីពីពាណិជកម្មផង ពីសេរីភាពផ្សព្វផ្សាយសាសនា (កាតូលីក) ផង ពីការបើកផ្លូវឲ្យកុប៉ាល់ចំបាំងបារាំង ចូលទៅដល់ទីក្រុងបឹងកកផង។ ខាងសៀម ក៏គេត្រូវការវត្តមានបារាំង មកនៅជិតខាងគេដែរ ដើម្បីជាការទប់ទល់និងពួកអង់គ្លេស ដែលកំពុងវាតទីអានុភាពខ្លាំងក្លាណាស់ មកលើដែនដីសៀម។ ជាបន្ទាប់មក រដ្ឋមន្ត្រីសៀម ក្រសួងទ័ពជើងទឹក និង ក្រសួងការបរទេស បានយកផែនទីនៃឆ្នេរសមុទ្រសៀម និងស្រុកខ្មែរ និងដែនកូសាំងស៊ីន ទៅពីគ្រោះជាមួយលោក ម៉ុងទីញី ឲ្យ ម៉ុងទីញី យល់អំពីប្រយោជន៍សេដ្ឋកិច្ច នៃ«កូត្រូល» (កោះត្រល់) ហើយឲ្យយកកោះនេះ ជាកម្មសិទ្ធិរបស់បារាំងទៅ។ លុះ ម៉ុងទីញី មកដល់ខែត្រកំពត គាត់បាន ឃើញថា កោះត្រល់ **«អាចរៀបចំ ជាផែរសមុទ្រមួយ យ៉ាងប្រសើរ និងជាទីតាំងពាណិជ្ជកម្មមួយយ៉ាងធំ នៅកណ្តាលដែនឥណ្ឌូចិនផង»**។ ប៉ុន្តែ ម៉ុងទីញី មិនចង់ធ្វើដំណើរ (ដោយលេសថាផ្លូវពិបាក) ទៅជួប **ព្រះបាទអង្គឌួង** ឯក្រុងឧត្តុង្គទេ ហើយគាត់ចាត់ឲ្យ លោកសង្ឃកាតូលីក ឈ្មោះ អារសែន អេសត្រេស (Arsène Hestrest) នាំយកទៅថ្វាយព្រះអង្គឌួង នូវសំបុត្រមួយ ដែលគាត់ស្នើឲ្យកម្ពុជា ប្រគល់ **«កោះត្រល់»** ឲ្យបារាំង ជាថ្នូរនឹងគំរូសន្ធិសញ្ញា ដែលបារាំង បានធ្វើជាមួយសៀម ពីខែសីហា មុននោះ។ ព្រះបាទ អង្គឌួង មិនព្រមទទួលសេចក្តីស្នើនេះទេ ដោយលោកយល់ថា សន្ធិសញ្ញាបែបហ្នឹង មិនបានធានាច្បាស់ លាស់ ចំពោះ«សន្តិសុខ» (ការរស់រានជានិច្ច) នៃកម្ពុជាទេ...។

ដោយឡែក នាសម័យនោះដែរ ពួកអង់គ្លេសក៏បាន មកពិនិត្យមើល **«កោះត្រល់»** ដែរ (**គេហៅថា «កោះឌូត** - Koh Doot») ហើយនិយាយថា ជា**«កោះមួយមានសារៈសំខាន់ណាស់ សំរាប់ការប្រើប្រាស់ នៃកងនាវាសមុទ្រ» នៅតាមផ្លូវដំណើរ ទៅក្រុងស៊ីងកាពួរ** (Singapour)។ ការពិត កោះត្រល់នេះ ជាកោះធំជាងគេបំផុត **មានទំហំប្រមាណ ៥៨០ គ.ម.ក្រឡា** នៅក្នុងឈូងសមុទ្រសៀម និងនៅមាត់ផ្លូវចូល នៃឈូងសមុទ្រហ្នឹងផង។

## ការដណ្តើមគ្នាគ្រប់គ្រង «កោះត្រល់»

នៅខាងខ្មែរវិញ កោះត្រល់ ស្ថិតក្រោមការគ្រប់គ្រងរបស់កម្ពុជា ដូចការបញ្ជាក់ពីទេសាភិបាលបារាំង នៃដែនកូសាំងស៊ីន ដែលសរសេរទៅរដ្ឋមន្ត្រីរបស់គាត់ នាឆ្នាំ ១៨៦៧ ថាអភិបាលយួន (វៀតណាម) នៃខែត្រហាទៀង **«មិនដែលបាន ចុះទៅមើលការងារអ្វី នៅកោះត្រល់ទេ»**។ នាថ្ងៃទី០៣ មករា ១៩១៣ គឺ ៣៦ ឆ្នាំបន្ទាប់មក អភិបាលបារាំង នៃខែត្រហាទៀងឈ្មោះ ហ្វួរនីយេ (Fournier) បានធ្វើរបាយការណ៍ ទៅទេសាភិបាលបារាំង នៃកូសាំងស៊ីនថា «បន្ទាប់ពីការស្រាវជ្រាវយ៉ាងល្អិតល្អន់មក ខ្ញុំមិនបានរកឃើញទេ នៅក្នុងកំណប់ឯកសារ នៃអធិការដ្ឋានយើង នូវឯកសារជាផ្លូវការណាមួយ ទោះមានទ្រង់ទ្រាយយ៉ាងណាក្តី ដែលបង្ហាញថា តើកោះណាខ្លះ ជាចំណុះនៃខែត្រហាទៀង គឺថា តើកោះណាខ្លះ ជារបស់កូសាំងស៊ីន ហើយកោះណាខ្លះទៀត ជារបស់កម្ពុជា»។ ចាប់ពីឆ្នាំ ១៩១៣ នោះដែរ គេបានផ្អើលម្តងទៀត អំពីប្រយោជន៍សេដ្ឋកិច្ច នៃកោះតាមឆ្នេរសមុទ្រខ្មែរ មានកោះត្រល់ជាអាទិ៍។ **លោកទេសាភិបាល នៃកូសាំងស៊ីន បានសរសេរសំបុត្រ**

**មួយ ចុះថ្ងៃទី០២ មករា ១៩១៤ ប្រាប់មក អ្នកតំណាងជាន់ខ្ពស់បារាំង នៅកម្ពុជា (le Résident supérieur du Cambodge) ថាលោកបានទទួលពាក្យស្នើជាច្រើន សុំសម្បទានដីធ្លី ដើម្បីការរុករករ៉ែ (នៅលើកោះទាំងនោះ) ជាមួយនឹងការរកឃើញទៀតថា «ទឹក ដែលនៅជុំវិញកោះទាំងនោះ មានត្រីរស់នៅសន្ធឹកសន្ធាប់ណាស់... (តែ)គ្មាននរណាទាញយកផល អំពីធនធានទាំងនេះ ដែលជាមូលធនមួយសំខាន់ណាស់ និងជាប្រយោជន៍ពិតប្រាកដ សម្រាប់អាណានិគម (បារាំង)»។ រីឯអ្នកតំណាងបារាំង នៅខែត្រកំពត ក៏បានទទួលពាក្យស្នើជាច្រើន សុំសម្បទានដីធ្លី ដើម្បីការរុករករ៉ែ នៅលើកោះ ដែលនៅក្រោមការគ្រប់គ្រង របស់គាត់ដែរ**។ ហេតុនេះ នាឆ្នាំ ១៩១៣ និង ១៩១៤ នោះ អ្នកទទួលការខុសត្រូវបារាំង នៅកូសាំងស៊ីន និងនៅកម្ពុជា បានប្តូរសំបុត្រទៅវិញទៅមក ទាមទារកម្មសិទ្ធិ នៃកោះផ្សេងៗនោះ តែលោកអគ្គទេសាភិបាលនៃឥណ្ឌូចិន ជាបន្តបន្ទាប់ ដែលជា «ចៅហ្វាយធំបំផុត» មិនបានសម្រេចអ្វីឡើយ ដោយពិតជាខ្លាចទាស់នឹងសន្ធិសញ្ញានានា រវាងបារាំង និងកម្ពុជា។ ទាល់តែ ២៥ ឆ្នាំបន្ទាប់មកទៀត ទើបលោក **ហ្ស៊ុល ប្រេវិយេ** (ដែលមកកាន់ការឥណ្ឌូចិន តាំងពី ខែកញ្ញា ១៩៣៦) **សម្រេចចិត្ត អំពីបញ្ហាហ្នឹង ដោយចេញសារាចរ ធ្វើខ្សែបន្ទាត់មួយ ចែក «កិច្ចរដ្ឋបាល» នៃកោះនានា ចុះថ្ងៃទី ៣១ មករា ១៩៣៩ ប្រាប់ទៅលោកទេសាភិបាលនៃកូសាំងស៊ីន។**

ការសំរេចរបស់ ប្រេវិយេ អំពីបញ្ហានេះ នៅឆ្នាំ ១៩៣៩ ពិតជាទាក់ទិននឹងស្ថានភាព នៃប្រទេសបារាំង នាសម័យនោះដែរ។ ចាប់ពីឆ្នាំ ១៩៣០ មក ប្រទេសបារាំង បានរងគ្រោះធ្ងន់ធ្ងរ និងវិបត្តិសេដ្ឋកិច្ច នៃ បស្ចិមប្រទេស ដែលជំរុញឲ្យមានការបះបោរ ជាបន្តបន្ទាប់ក្នុងសង្គម នាឆ្នាំ១៩៣៤ និងបណ្តាលឲ្យកើតវិបត្តិនយោបាយ ដែលធ្វើឲប្រទេសទាំងមូល ចុះទន់ខ្សោយ ហើយរលំទាំងស្រុងយ៉ាងរហ័ស នៅមុខការ វាយរាតត្បាត នៃទ័ពអាល្លឺម៉ាញ (អាល្លឺម៉ង់) របស់ហ៊ីត្លែរ នាខែឧសភា ឆ្នាំ១៩៤០។ ក្នុងរយៈកាលនោះ នៅឯឥណ្ឌូចិន ក៏ដូចនៅប្រទេសបារាំងដែរ ពួកបារាំង គ្រាន់តែខំទប់ខ្លួន ឲ្យបាននៅឈរជើង ដោយគ្មានគម្រោងការអ្វីធំដុំទេ ក្នុងការរង់ចាំមើល ការវិវត្តិន៍នៃព្រឹត្តការណ៍ នៅទ្វីបអឺរ៉ុប និងនៅក្នុងពិភពលោក។

ព្រឹត្តការណ៍ធំមួយ នាថ្ងៃទី ៧ កក្កដា ១៩៣៧ កងទ័ពជប៉ុន ចូលវាយលុកប្រទេសចិន ផ្នែកខាងកើត ហើយបានកាន់កាប់ទីក្រុងស៊ាងហៃ នាខែវិច្ឆិកា រួចវាយយកបាន រដ្ឋធានីណាន់គីង (ណានជីង) ទៀត។

នៅក្នុងឯកសារបារាំងមួយ នៃនាយកដ្ឋានកិច្ចការនយោបាយ ចុះលេខ ៣៦៧-អាប៉េអ៊ី ស្តីពីកោះនានា នៅក្នុងឈូងសមុទ្រសៀម គេបានសរសេរថា *«សារាចរ របស់លោកអគ្គទេសាភិបាល ប្រេវិយេ ចុះថ្ងៃទី ៣១ មករា ១៩៣៩ បានធ្វើឡើង ស្របតាមការចាំបាច់ នៃកិច្ចការពារឥណ្ឌូចិនដែរ ដោយហេតុថា នាពេលនោះ ជប៉ុន បានកាន់កាប់ប្រទេសចិន ផ្នែកខាងកើតហើយ ហើយជាពេលដែលសង្គ្រាម នៅមហាសាគរប៉ាស៊ីហ្វិក បានចាប់ផ្តើមហើយផង»*។ នាពេលនោះទៀត កងទាហានជើងទឹកបារាំង (នៅឥណ្ឌូចិន) ក៏បានទទួលបញ្ជាឲ្យ «ត្រួតពិនិត្យទូក-កុប៉ាល់ទាំងអស់ កុំឲ្យមានការដឹកជញ្ជូនគ្រឿងសព្វាវុធ ទៅឲ្យពួកបះបោរ ឬ ឲ្យពួកចូលដៃនឹងកងកម្លាំងជប៉ុនឡើយ»។ ប៉ុន្តែនៅក្នុង «សារាចរ»របស់គាត់ លោក ប្រេវិយេ មិនបានលើកអំពីបញ្ហានយោបាយ និងយោធាទាំងនេះ ធ្វើជាការសំអាងអ្វីទេ។

## ភាពច្របូកច្របល់ក្នុងសារាចរ «ប្រេវិយេ»

យើងបានឃើញថា ដោយហេតុមានការទាមទារជាយូរមកហើយ ពីព្រះបាទ **អង្គឌួង** ពួកបារាំង បានទុកកោះនានា នៃឆ្នេរសមុទ្រ គឺទាំង «កោះត្រល់» រហូតដល់ប្រជុំកោះក្រចកសេះ (ពូឡូប៉ង់យ៉ង) ឲ្យនៅក្រោមអំណាចនៃកម្ពុជា។ រីឯ «សារាចរ» របស់លោក ប្រេវិយេ គឺជាការសម្រេចចិត្តម្នាក់ឯង - «ខ្ញុំសម្រេច...» - នៃអគ្គទេសាភិបាលនៃឥណ្ឌូចិន ដោយគ្មានការយល់ព្រមពីអាជ្ញាធរខ្មែរ (ភាគីកម្ពុជា)ទេ ហើយនេះជាការបំពានយ៉ាងជាក់ស្តែង លើសន្ធិសញ្ញានានា រវាងបារាំង និងកម្ពុជា នាទសវត្សរ៍ ១៨៧០។ ហេតុនេះ ដើម្បីបិទបាំងការរំលោភអំណាចរបស់គាត់ និងដើម្បីដាក់កម្រិតដល់ការអនុវត្ត នៃសេចក្តីសម្រេចចិត្តនោះផង លោក ប្រេវិយេ បានទទួលស្គាល់ជាបឋមបំផុតថា «កោះទាំងនោះ នៅតាមបណ្តោយឆ្នេរសមុទ្រកម្ពុជា» និងថា **«តាមការសមហេតុផល និងតាមស្ថានភាពភូមិសាស្ត្រ» កោះទាំងនោះ ត្រូវនៅក្រោមការគ្រប់គ្រង នៃប្រទេសកម្ពុជា។** បន្ទាប់គាត់បញ្ជាក់ថា សេចក្តីសម្រេចចិត្តហ្នឹង គ្រាន់តែបែងចែក **«អំណាចរដ្ឋបាល និងប៉ូលីស** នៅលើកោះ រវាងកូសាំងស៊ីន និងកម្ពុជាប៉ុណ្ណោះ» តែគាត់មិនអារកាត់ លើបញ្ហាកម្មសិទ្ធិនៃកោះទេ ដែលថា *«ត្រូវបម្រុងងទុកទាំងស្រុងដដែល»* - ប្រហែលដើម្បីសំរន់ចិត្ត របស់ពួកកូសាំងស៊ីន ជាគ្នីគ្នារបស់គាត់។

យើងឃើញថា សេចក្តីសម្រេចចិត្តហ្នឹង វាប្លែកខុសពីសេចក្តីសម្រេចចិត្តនានា នៃអគ្គទេសាភិបាលដ្ឋាននៃឥណ្ឌូចិន ដោយសារការច្របូកចូលគ្នា នូវជំនឿច្បាស់លាស់ផង នូវការសំអាងកំប៉ិចកំប៉ុកផង («ការសម្រួលដំណើរ» នៃអ្នកចង់ទាក់ទង និងរដ្ឋការកូសាំងស៊ីន) ជាមួយនឹងការទុកប្រចាំ នៃម្ចាស់សេចក្តីផង ដែលជាលក្ខណៈនៃការសម្រេចចិត្ត ជាបណ្តោះអាសន្នប៉ុណ្ណោះ ឲ្យស្របតាមទេសៈ កាលៈអសន្តិសុខ នៅក្នុងតំបន់។

ម៉្យាងទៀត ខ្សែបន្ទាត់នៃការបែងចែកសោត គឺជាការបង្កើតថ្មីមួយ ក្នុងរឿងដែនសមុទ្រ៖ គឺមិនមែនជាខ្សែបន្ទាត់ត្រង់រហូតទេ តែជាខ្សែដែលចេញពីដែនដី យ៉ាងត្រង់មក រួចបត់ដូចជាផ្លែកណ្តៀវ ទៅព័ទ្ធចាប់យកកោះត្រល់ ឲ្យទៅកូសាំងស៊ីន ហើយឈប់ត្រឹមហ្នឹង។ តាមធម្មតា គឺគ្មានអ្នកនីតិសាស្ត្រហ្មត់ចត់ណាម្នាក់យល់ថា ការសម្រេចិត្តបែបនេះ មានតម្លៃអ្វីទេ។ ហេតុនេះ **សារាចរ «ប្រេវិយេ» ត្រូវបានកម្ពុជា ច្រានចោលជានិច្ច បន្ទាប់ពីកម្ពុជាបានឯករាជ្យ នាឆ្នាំ ១៩៥៣។** រហូតមកដល់ឆ្នាំ ១៩៧៩ (ដែលយួន ចូលកាន់កាប់កម្ពុជា) រដ្ឋាភិបាលខ្មែរជាបន្តបន្ទាប់ទាំងអស់ តែងតែចាត់ទុក «កោះត្រល់» ប្រជុំកោះក្រចកសេះ (ពូឡូប៉ង់យ៉ង) និងកោះវៃ (ពូឡូវៃ) នៅក្នុងដែនសមុទ្រកម្ពុជា ជានិច្ច។

បន្ទាប់ពីបារាំង រំលាយអាណានិគម នាឆ្នាំ ១៩៤៩ និងបន្ទាប់ពីបានឯករាជ្យ មកដល់ឆ្នាំ ១៩៧៥ ទោះបីគេបានធ្វើការបម្រុងទុក (des réserves) និងការទាមទារតាមផ្លូវទូត ជាច្រើនសន្ទឹកក្តី ក៏កម្ពុជា មិនដែលប្រើកម្លាំងទ័ព ដើម្បីទៅដណ្តើមយក «កោះត្រល់» មកកាន់កាប់ផ្ទាល់ដៃវិញទេ។ ការទាមទារ តាមផ្លូវតុលាការអន្តរជាតិ ដូចក្នុងរឿងប្រាសាទព្រះវិហារ ក៏គ្មានដែរ។ ប៉ុន្តែសម័យ ប៉ុល ពត ដែលយល់អំពីសារៈសំខាន់នៃស្ថានភាពយុទ្ធសាស្ត្រ នៃកោះត្រល់ និងកោះជិតខាងឯទៀតនោះ **បានឲ្យកងទ័ពចូលទៅ ប្រយុទ្ធនឹងកងទ័ពយួន នាដើមខែ ឧសភា ១៩៧៥ ដោយបានកាន់កាប់ «កោះត្រល់» មួយភាគធំ និងកោះក្រចកសេះ។**

**ការចរចាគ្នា រវាង ប៉ុល ពត និងយួន នៅក្រុងហាណូយ នាខែ មិថុនា ១៩៧៥ បានបន្ធូរ បរិយាកាសខ្លះដែរ តែដល់ថ្ងៃទី ៤ មករា ១៩៧៦ ការប្រយុទ្ធគ្នាយ៉ាងខ្លាំងមួយទៀត បានផ្ទុះឡើង រវាង កងទ័ពខ្មែរក្រហម នៅកោះត្រល់ ជាមួយកងទ័ពជើងទឹក និងជើងអាកាសយួន។ ពួកខ្មែរក្រហម ត្រូវដកខ្លួនទាំងអស់ ចេញពីកោះត្រល់ ប៉ុន្តែការបរាជ័យនេះ មិនមានន័យថា កម្ពុជា ត្រូវបាត់បង់សិទ្ធិដ៏ត្រឹមត្រូវ របស់ខ្លួន ទៅលើកោះត្រល់ និងកោះក្រចកសេះ ទាំងនោះដែរទេ។**

យៀកណាម បានកាន់កាប់កោះទាំងនោះ ដោយកម្លាំងរហូតដល់ ខែធ្នូ ឆ្នាំ ១៩៧៨ ដែលគេបានសម្រេចចិត្ត ចូលវាយប្រហារកម្ពុជាទាំងមូល។ ក្នុងពេលគេកាន់កាប់កម្ពុជា យួនបានសម្រេចកាត់យក **«កោះត្រល់ និងក្រុមកោះក្រចកសេះ» បញ្ចូលទៅក្នុងយៀកណាម ដោយគ្មានសំអាងលើកត្តាអ្វីទេ ក្រៅពីយោងតាម «សភាពការជាក់ស្តែង»** (គឺការកាន់កាប់របស់គេ ជាស្រេចហើយ) តាមរយៈកិច្ចព្រមព្រៀងមួយ ចុះថ្ងៃទី ០៧ កក្កដា ១៩៨២ ជាមួយបុគ្គលម្នាក់ ឈ្មោះ ហ៊ុន សែន {រដ្ឋមន្ត្រីការបរទេសនៃ រដ្ឋបាលក្រុងភ្នំពេញ ដែលយៀកណាម លើកបន្តុបឲ្យកាន់អំណាច}។ ក្នុងកិច្ចព្រមព្រៀងនោះ គេបានបង្កើតនៅមុខ «កោះត្រល់» នូវ «សមុទ្រផ្ទៃក្នុងរួមគ្នា» រវាងយៀកណាម-កម្ពុជា មានទំហំប្រមាណ ១០.០០០ គ.ម.ក្រឡា (មួយម៉ឺន) ដែលគេហៅថា «តំបន់ទឹកប្រវត្តិសាស្ត្រ» ដែលមានលទ្ធផលជាការពង្រីកអធិបតេយ្យយួន ចូលមកជ្រៅទៀត ក្នុងដែនសមុទ្រខ្មែរ ក្នុងនាមនៃការចាំបាច់ នៃ«កិច្ចការពារជាតិ នៃប្រទេសទាំងពីរ»។ **នេះគឺជាការជាក់ស្តែងដែរ នៃកិច្ចព្រមព្រៀងមួយ មិនស្មើរភាពគ្នា និងខុសច្បាប់អន្តរជាតិទាំងស្រុង** ដែលត្រូវបានអង្គការសហប្រជាជាតិ (អ.ស.ប.) **បានបរិហារ {មិនទទួលស្គាល់}** នាឆ្នាំ១៩៨៦ ហើយត្រូវកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ស្តីពីកម្ពុជា ឆ្នាំ១៩៩១ **បញ្ជាឲ្យលុបចោល**។

## ខ្មែរត្រូវយកកោះត្រល់ មកវិញ

យើងបានឃើញថា **យៀកណាមកុម្មុយនីស្ត ដែលបានក្លាយជាមហាអំណាចយោធា មិនទទួលស្គាល់ សារៈសំខាន់ នៃខ្សែបន្ទាត់ «ប្រេវិយេ»** ទេ។ ប៉ុន្តែ ការមិនទទួលស្គាល់ខ្សែបន្ទាត់នេះ ពីខាងកម្ពុជាវិញ ក៏ជាការសមស្រប និងគោលការណ៍ច្បាប់ ដែលកើតពីការសម្រេចរបស់បារាំង រំលាយអាណានិគម កូសាំងស៊ីន របស់គេនាឆ្នាំ ១៩៤៩ ដែរ។ យើងបានឃើញខាងលើនេះថា **ពួកអាណានិគមនិយមបារាំង រួមទាំងលោកប្រេវិយេ នោះផង បានដឹងច្បាស់ថា «កោះត្រល់»ជាពិសេស មិនមែនជាកោះធម្មតាទេ តែវាមានលក្ខណៈតាមភូគព្ភសាស្ត្រ ដូចជាទៀបកោះ ដែលមានមួយភាគលិចទឹក ព្រោះវាជាដីបណ្តោរ ចុះមកពីជួរភ្នំក្រវ៉ាញ នៃកម្ពុជា។**

អាស្រ័យហេតុនេះហើយ ទើបបារាំងទាំងនោះ មិនហ៊ានសម្រេចយក «កោះត្រល់» ទៅបញ្ចូលក្នុងដែនកូសាំងស៊ីន ទោះបីគេមានអំណាចធំធេង លើកម្ពុជា តាំងពីឆ្នាំ ១៨៦៣ មកក្តី។ ម៉្យាងទៀត សារាចរ«ប្រេវិយេ» ដែលគ្រាន់តែជាការសម្រេចចិត្ត នៃកិច្ចការរដ្ឋបាលផ្ទៃក្នុង មិនមានកម្លាំងដូចសន្ធិសញ្ញា អន្តរជាតិ ឬដូចច្បាប់ផ្ទៃក្នុងរបស់កម្ពុជាទេ ពីព្រោះកម្ពុជា មិនមែនជាអាណានិគមរបស់បារាំងទេ តែជារដ្ឋមួយ ដែលបារាំង ធ្វើជា

អ្នកអាណាព្យាបាល (អ្នកការពារ ក្នុងកិច្ចការក្រៅប្រទេស)។ ជាពិសេស ខ្សែបន្ទាត់«ប្រេវិយេ» មានលក្ខណៈច្បាស់ថា ជាខ្សែបន្ទាត់ នៃការរំលោភអំណាច និងជាការកំណត់ បណ្តោះអាសន្ន ដែលត្រូវរលាយបាត់ ជាស្វ័យប្រវត្តិ នាពេលដែលបារាំង រំលាយអាណានិគម កូសាំងស៊ីន របស់ខ្លួនដែរ។ **ហេតុនេះ ខ្សែបន្ទាត់ «ប្រេវិយេ» មិនអាចចាត់ទុកថាជា ខ្សែបន្ទាត់ព្រំដែនសមុទ្រ រវាងកម្ពុជានិងយៀកណាមទេ** ហើយគេមិនត្រូវចាត់ទុកវា យ៉ាងហ្នឹងឡើយ។ **ការពិត កោះត្រល់ និងកោះឯទៀត នៅជិតឆ្នេរសមុទ្រខ្មែរ សុទ្ធជាដីដែលដុះបន្តតាមធម្មជាតិរបស់កម្ពុជា គឺថាជារបស់ប្រជាជាតិ ដែលនៅជិតកោះទាំងនេះ ហើយវាកំណត់ដែនទឹកសមុទ្រ និងព្រំដែនអធិបតេយ្យ នៃប្រជាជាតិហ្នឹងតែម្តង** ។ សារៈសំខាន់បំផុត នៃកោះទាំងនោះ មិននៅក្នុងរឿងប្រយោជន៍សេដ្ឋកិច្ចទេ (ដូចជាធនធានជលផល និងធនធានរ៉ែ ឬ ប្រេងកាត ជាយថាហេតុ) តែនៅក្នុងរឿងយុទ្ធសាស្រ្តយោធា ត្បិតកោះទាំងនោះ សុទ្ធសឹងជាប៉ុស្តិ៍ជួរមុខ នៃកិច្ចការពារជាតិរបស់កម្ពុជា។ ខ្មែរត្រូវតែខំប្រឹងប្រែងរកគ្រប់មធ្យោបាយ យកកោះត្រល់ និងកោះឯទៀតទាំងនោះ មកគ្រប់គ្រងវិញជាចាំបាច់។

ទីក្រុងប៉ារីស ថ្ងៃទី១ តុលា ២០១២

**ឌី ការ៉េត អនុប្រធាន**

ជ. គណៈកម្មាធិការ ព្រំដែនកម្ពុជាប្រចាំប្រទេសបារាំង និងក្នុពិភពលោក